ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ០១/២៤ ក.ធ.ស.បញ្ញថ

# បទប្បញ្ញត្តិទូទៅ

## សម្រាប់ការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទាំងពីរកម្រិត

## ឆ្នាំសិក្សា ២០២៣-២០២៤

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ វិន័យ នៃការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ-ពុធ-ព្រហស្បតិ៍ ១២-១៣-១៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៦-៧-៨ ខែកុម្ភៈ ឆ្នាំ២០២៤ និងការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅថ្ងៃពុធ-ព្រហស្បតិ៍-សុក្រ ១២-១៣-១៤កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២១-២២-២៣ ខែកុម្ភៈ ឆ្នាំ២០២៤ ឱ្យបានល្អប្រសើរ បេក្ខសមណៈ បេក្ខជន ត្រូវគោរពបទប្បញ្ញត្តិទូទៅ សម្រាប់ការប្រឡងដូចខាងក្រោម៖

### I-ប្រការដែលបេក្ខសមណៈ បេក្ខជន ត្រូវអនុវត្ត

១-ត្រូវមកដល់មណ្ឌលប្រឡង ឱ្យបានមុនដំណើរការនៃការប្រឡង ៣០ នាទី។

២-ត្រូវឃ្លុំចីវរឬស្លៀកពាក់ឯកសណ្ឋានសិស្ស ដាក់អាវក្នុងខោឬសំពត់ឱ្យបានត្រឹមត្រូវក្នុងមណ្ឌលប្រឡង។

៣-ត្រូវយកសលាកបត្រឯកត្តជន បង្ហាញអនុរក្សមុននឹងចូលបន្ទប់ប្រឡង។

៤-សម្ភារប្រើប្រាស់ដែលក្រសួងធម្មការនិងសាសនា អនុញ្ញាតឱ្យបេក្ខសមណៈ បេក្ខជន យកចូលបន្ទប់ប្រឡងបាន មានប៊ិកពណ៌ខៀវ ខ្មៅដៃ បន្ទាត់ និងជ័រលុប។

៥-ត្រូវអនុវត្តតាមការណែនាំរបស់គណៈមេប្រយោគនិងអ្នកមានសមត្ថកិច្ចថែរក្សាសណ្តាប់ធ្នាប់។

៦-ត្រូវគោរពតាមការណែនាំរបស់អនុរក្ស គង់ឬអង្គុយឱ្យចំលេខតុ បំពេញលើសន្លឹកកិច្ចការដែលអនុរក្សបានចែកឱ្យនិងប្រគល់កិច្ចការជូនអនុរក្សវិញពេលដល់ម៉ោង ទោះបីសន្លឹកកិច្ចការនោះបានធ្វើឬពុំបានធ្វើក៏ដោយ។

៧-ត្រូវបំពេញឈ្មោះ ថ្ងៃខែឆ្នាំកំណើត លេខបន្ទប់ លេខតុ មណ្ឌលប្រឡង និងចុះហត្ថលេខារាល់ម៉ោងលើបញ្ជីសម្រង់វត្តមាន មុននឹងធ្វើវិញ្ញាសា។

៨-ត្រូវប្រគល់សន្លឹកកិច្ចការជូនអនុរក្សតាមថិរវេលាកំណត់។

៩-ត្រូវរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយប្រកបដោយក្រមសីលធម៌ខ្ពស់និងត្រូវគោរពឱ្យបានត្រឹមត្រូវនូវបទប្បញ្ញត្តិនៃការប្រឡង។

### II-ប្រការដែលបេក្ខសមណៈ បេក្ខជន មិនត្រូវអនុវត្ត

១-មិនត្រូវមកដល់មណ្ឌលប្រឡងក្រោយជួងទី២។

២-មិនអនុញ្ញាតឱ្យចូលក្នុងបន្ទប់ប្រឡង មុនអនុរក្សហៅឈ្មោះឡើយ។

៣-មិនត្រូវយកសម្ភៀត ថង់យាម សៀវភៅ និងសំណៅឯកសារផ្សេងៗ ចូលក្នុងបន្ទប់ប្រឡង



ស្ថនច្បារសម្តេច ហ៊ុន សែន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh

បើចាប់បានមិនប្រគេន ប្រគល់ជូនវិញឡើយ។

៤-គ្រប់សំណៅឯកសារ ឧបករណ៍អេឡិចត្រូនិក និងទូរសព្ទដៃគ្រប់ប្រភេទ ដែលលាក់ជាប់នឹងខ្លួន ដោយមានបំណងទុកលួចចម្លងនិងប្រើប្រាស់ នឹងមិនអនុញ្ញាតឱ្យចូលប្រឡងជាដាច់ខាត ហើយត្រូវបានកំណត់ឱ្យធ្លាក់ លើកលែងតែបេក្ខសមណៈ បេក្ខជន នោះប្រគល់ឱ្យគណៈមេប្រយោគមុនចូលមណ្ឌលប្រឡងឬបន្ទប់ប្រឡង។

៥-គ្រប់សំណៅឯកសារ ឧបករណ៍អេឡិចត្រូនិក និងទូរសព្ទដៃគ្រប់ប្រភេទ គណៈមេប្រយោគមិនទទួលខុសត្រូវរាល់ការបាត់បង់និងខូចខាតឡើយ។ ចំពោះឧបករណ៍អេឡិចត្រូនិកនិងទូរសព្ទដៃគ្រប់ប្រភេទ ដែលបានប្រគល់ឱ្យគណៈមេប្រយោគមុនចូលបន្ទប់ប្រឡង ត្រូវរក្សាទុករហូតដល់បញ្ចប់ដំណើរការប្រឡង។

៦-មិនត្រូវឱ្យអ្នកដទៃប្រឡងជំនួសឬសរសេរលើសន្លឹកកិច្ចការរបស់ខ្លួនជាដាច់ខាត។

៧-មិនត្រូវប្រើពាក្យសម្ដីនិងអាកប្បកិរិយា ដែលនាំឱ្យខូចសណ្ដាប់ធ្នាប់ របៀបរៀបរយនៃការប្រឡងឬប៉ះពាល់ដល់កិត្តិយសរបស់គណៈមេប្រយោគ។

៨-មិនត្រូវធ្វើចម្លើយវិញ្ញាសាលើសន្លឹកកិច្ចការណាដែលគ្មានចុះហត្ថលេខារបស់អនុរក្ស។

៩-មិនត្រូវធ្វើសញ្ញាសម្គាល់លើសន្លឹកកិច្ចការ ឱ្យស្គាល់អាតតដ្ឋានរបស់ខ្លួន ដូចជាសរសេរអក្សរប្លែកគួ ធ្វើសញ្ញាផ្សេងៗ គូសបន្ទាត់ខុសប្រក្រតីឬសរសេររំលងបន្ទាត់។

១០-មិនត្រូវដើរចេញពីកន្លែងដោយគ្មានការអនុញ្ញាតពីអនុរក្សឬអានឮខ្លាំងៗ នូវអ្វីដែលខ្លួនសរសេររួចហើយឱ្យឮដល់អ្នកជិតខាង។

១១-មិនត្រូវចម្លងប្រធានវិញ្ញាសាចូលក្នុងសន្លឹកកិច្ចការ ឬក្រដាសដទៃទៀតនិងមិនត្រូវបោះប្រធានវិញ្ញាសាចេញក្រៅបន្ទប់ប្រឡងឡើយ។

១២-មិនត្រូវប្ដូរសន្លឹកកិច្ចការនិងក្រដាសព្រាងគ្នា ផ្ទៀងផ្ទាត់ចម្លើយគ្នា ចម្លងគ្នាឬដាក់សន្លឹកកិច្ចការឆ្ងាយពីខ្លួនដែលបង្កឱ្យអ្នកដទៃមើល អូស ឬឆក់យកបាន។

១៣-មិនត្រូវឱ្យសន្លឹកកិច្ចការឬសំណៅក្រដាសព្រាងរបស់ខ្លួនទៅអ្នកដទៃចម្លងជាដាច់ខាត។

១៤-មិនត្រូវដណ្ដើមសន្លឹកកិច្ចការអ្នកដទៃមកចម្លង ឬឱ្យអ្នកដទៃសរសេរលើសន្លឹកកិច្ចការរបស់ខ្លួន។

១៥-មិនត្រូវចេញទៅយកសំណៅឯកសារចូលក្នុងបន្ទប់ប្រឡងឬបង្កជម្លោះ គំរាមកំហែងដល់អនុរក្សនិងបេក្ខសមណៈ បេក្ខជនដទៃទៀតឡើយ។

១៦-មិនត្រូវលាក់ឬហែកសន្លឹកកិច្ចការរបស់អ្នកដទៃឬរឹងទទឹងមិនព្រមប្រគល់សន្លឹកកិច្ចការជូនអនុរក្ស។

បេក្ខសមណៈ បេក្ខជនណាដែលប្រព្រឹត្តខុសបទប្បញ្ញត្តិទូទៅខាងលើនេះ នឹងត្រូវដកបេក្ខភាពចេញពីការប្រឡង។

ថ្ងៃ អង្គារ ១៣ រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

ចាយ_បូរិន